# សន្លឹកពត៌មានសាធារណៈ

Ottawa County Health Department

## ជំងឺគ្រុនផ្តាសាយធំ

**តើជំងឺគ្រុនផ្តាសាយធំជាអ្វី ?**

ជំងឺគ្រុនផ្តាសាយធំ ជាជំងឺបណ្តាលមកពីវីរុសម្យ៉ាង ដែលធ្វើទុក្ខជាសំខាន់លើច្រមុះ បំពង់ក និងសួត ។ តាមធម្មតា វាកើតឡើងមួយរំពេច និងអាចស្ថិតនៅរហូតដល់មួយសប្តាហ៏ ឬលើស ។

**តើអ្នកណាខ្លះអាចកើតជំងឺគ្រុនផ្តាសាយធំ ?**

អ្នកណាក៏ដោយ ក៏អាចមានជំងឺគ្រុនផ្តាសាយដែរ ។ ប៉ុន្តែ មនុស្សចាស់ អ្នកមានជំងឺរ៉ាំរៃ ស្រ្តីមានផ្ទៃពោះ និងកុមារអាយុរវាង ៦ ខែ ទៅ ២ ឆ្នាំ អាចទទួលរងនូវផលវិបាកពីជំងឺនេះខ្លាំងជាងគេ ។

**តើជំងឺគ្រុនផ្តាសាយធំឆ្លងតាមរបៀបណា ?**

ជំងឺគ្រុនផ្តាសាយធំ ឆ្លងជាពិសេសពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត តាមការក្អក និងកណ្តាស ។

**តើជំងឺគ្រុនផ្តាសាយធំ អាចមានរោគសញ្ញាអ្វីខ្លះ ?**

រោគសញ្ញានៃជំងឺគ្រុនផ្តាសាយធំ ច្រើនលេចចេញក្នុងរយៈពេល ៣ថ្ងៃក្រោយពីការឆ្លងមេរោគនេះ :

- គ្រុនក្តៅ ( ច្រើនក្តៅខ្លាំង )
- អស់កំលាំង
- ឈឺក្បាល
- ឈឺចុកចាប់សាច់ដុំ
- ក្អកស្ងួត
- ហៀរសំបោរ
- រងាររស្រៀវស្រាញ
- ឈឺបំពង់ក

**តើគេស្រាវជ្រាវរកជំងឺគ្រុនផ្តាសាយធំតាមរបៀបណា ?**

ជាការពិបាកនឹងប្រាប់អោយបានច្បាស់ ថាតើអ្នកមានជំងឺគ្រុនផ្តាសាយធំ ឬទេដោយសំអាងលើតែរោគសញ្ញាតែមួយមុខ ។ វេជ្ជបណ្ឌិតអាចធ្វើតេស្ត ផ្សេងៗ ដើម្បីពិនិត្យមើលថាតើអ្នកមានជំងឺគ្រុនផ្តាសាយធំឬទេ បើសិនជាអ្នកទៅពិនិត្យក្នុងរយៈពីរបីថ្ងៃដំបូងនៃជំងឺ ។

**តើគេព្យាបាលជំងឺគ្រុនផ្តាសាយធំយ៉ាងដូចម្តេច ?**

ការព្យាបាលដ៏ប្រសើរបំផុតនោះគឺ សំរាកនៅផ្ទះ និងផឹកជាតិទឹកអោយបានច្រើន ។ ថ្នាំទិញនៅឱសថស្ថាន ក៏អាចជួយបានដែរ ប៉ុន្តែយកល្អ ត្រូវទៅពិគ្រោះជាមួយវេជ្ជបណ្ឌិតសិន ជាពិសេស មុនអោយថ្នាំផ្សេងៗទៅកុមារលេប ។

**តើគេអាចបង្ការជំងឺគ្រុនផ្តាសាយ យ៉ាងដូចម្តេច ?**

- ត្រូវខ្ទប់មាត់របស់អ្នក នៅពេលក្អក និងកណ្តាស
- ត្រូវជៀសវាងប៉ះពាល់ជាមួយអ្នកឆ្លងជំងឺនេះ
- ត្រូវឧស្សាហ៏លាងសំអាតដៃ
- ត្រូវចាក់ថ្នាំវ៉ាក់សាំងបង្ការជំងឺគ្រុនផ្តាសាយធំ ជារៀងរាល់ឆ្នាំ

**តើអ្នកណាខ្លះគួរចាក់ថ្នាំវ៉ាក់សាំងបង្ការជំងឺគ្រុនផ្តាសាយធំ ?**

- មនុស្សធំ និងកុមារដែលមានជំងឺរ៉ាំរៃ
- អ្នកនៅក្បែរជាមួយអ្នកដែលងាយឆ្លង ឬអ្នកកើតជំងឺរ៉ាំរៃ
- អ្នកដែលមានអាយុ ៥0 ឆ្នាំឡើង
- កុមារដែលមានអាយុ ៦ ទៅ ២៣ខែ
- អ្នកនៅក្បែរជាមួយកុមារដែលមានអាយុ ៦ ទៅ ២៣ខែ
- ស្រ្តីមានផ្ទៃពោះក្នុងត្រីមាសទី ២ ឬទី៣ នៅអំឡុងរដូវមានជំងឺគ្រុនផ្តាសាយធំ
- បុគ្គលិកសុខាភិបាល

*សំគាល់ : អ្នកដែលមានអាយុ៦៥ឆ្នាំឡើង ឬមានបញ្ហាសុខភាពផ្សេងៗ គួរចាក់វ៉ាក់សាំងបង្ការជំងឺរលាកទងសួត ផងដែរ ។*

**សំរាប់ពតិមានបន្ថែមស្តីអំពីជំងឺគ្រុនផ្តាសាយធំ សូមទាក់ទង :**

Ottawa County Health Department
www.miOttawa.org
Centers for Disease Control and Prevention
www.cdc.gov/flu/
ទូរស័ព្ទ : (888) 246-2675

12251 James St., Suite 400
Holland, MI 49424
ទូរស័ព្ទ : (616) 396-5266
ទូរសារ : (616) 393-5643
វ៉ិបសាយ : www.miOttawa.org